# គំនិតពាល

| | |
|---|---|
| **បុត្តា មត្ថិ ធនមត្ថិ** | **ឥតិ ពាលោ វិហញ្ញតិ** |
| **អត្តា ហិ អត្តនោ នត្ថិ** | **កុតោ បុត្តា កុតោ ធនំ។** |

*ជនពាលតែងក្តៅក្រហាយថា　　អាត្មាមានកូននិងមានទ្រព្យ*
*ព្រោះមិនបានគិតឲ្យសព្វគ្រប់　　មានកូននិងទ្រព្យមកពីណា ។*
*តាមពិតខ្លួនឯងក៏គ្មានដែរ　　ប៉ុន្តែចេះតែនាំគ្នាថា*
*មានកូនមានទ្រព្យមានអត្តា　　នេះគ្រាន់តែជាគំនិតពាល ៕*

---

# ត្រូវរៀបចំខ្លួនតាមវ័យ

| | |
|---|---|
| *វ័យចាស់ត្រូវស្វះស្វែងរកធម៌* | *ជាទ្រព្យបវរកុំបីខាន* |
| *ទាន សីល ភាវនា ល្អចំណាន* | *ជួយយើងឲ្យបានក្តីសុខា ។* |
| *ត្រដាក់កាយចិត្តនាមនុស្ស* | *លុះស្លាប់ទៅកើតជាទេវតា* |
| *សោយសុខសម្បត្តិទិព្វថ្លៃថ្លា* | *វិមានអស្ចារ្យឥតប្រៀបបាន ។* |
| *ផុតទុក្ខបានសុខថ្លៃវិសេស* | *ត្រូវលះកិលេសចូលនិព្វាន* |
| *ធ្វើវិបស្សនាកុំបីខាន* | *លោកអ្នកនឹងបានសម្រេចអើយ ។* |